ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាពនិងការធ្វើអនុប្បយោគ លើផ្ទៃដីទំហំ ២៩១ (ពីររយកៅសិបមួយ )ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិ ព្រះមុនីវង្ស «បូកគោ» ភូមិសាស្ត្រសង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៦២ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែប្រែឧទ្យានជាតិព្រះមុនីវង្ស «បូកគោ»
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .–**

ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងលើផ្ទៃដីទំហំ ២៩១ (ពីររយកៅសិបមួយ)ហិកតា ស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» ភូមិសាស្ត្រសង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដូចមានផែនទីភនិងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន សុគន្ធ ខេភីតូ្លប៊ិល អ៊ិនវេសម៉ិន ខូ អិលធីឌី ដើម្បីបន្តរៀបចំបំពេញបែបបទនីតិវិធីជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២ .–**

ត្រូវបានធ្វើអនុប្បយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋលើផ្ទៃដីទំហំ ២៩១ (ពីររយកៅសិបមួយ) ហិកតា ដូចមានចែងក្នុងមាត្រា១នៃអនុក្រឹត្យនេះ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្រោមលក្ខខណ្ឌជួលឱ្យក្រុមហ៊ុន សុគន្ធខេភី តូ្លប៊ិល អ៊ិនវេសម៉ិន ខូ អិលធីឌី សម្រាប់វិនិយោគ លើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសនិងអភិវឌ្ឍន៍ទេសចរណ៍ ដែលត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថានជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងចំណុចនិយាមការឧបសម្ព័ន្ធនៃលិខិតលេខ២៦០.អនក្រ..បក...ថ្ងៃអង្គារ ១៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២៣

| Id | X | Y | Id | X | Y | Id | X | Y | Id | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 384909.571 | 1173603.985 | 36 | 384587.920 | 1174180.065 | 71 | 385514.062 | 1174642.247 | 106 | 386742.089 | 1175361.942 |
| 2 | 384845.683 | 1173699.282 | 37 | 384591.131 | 1174190.619 | 72 | 385501.468 | 1174706.098 | 107 | 386706.334 | 1175183.438 |
| 3 | 384738.001 | 1173752.484 | 38 | 384589.267 | 1174252.280 | 73 | 385508.605 | 1174758.094 | 108 | 386681.472 | 1175059.306 |
| 4 | 384704.718 | 1173782.119 | 39 | 384593.014 | 1174266.434 | 74 | 385548.805 | 1174952.133 | 109 | 386679.762 | 1175053.860 |
| 5 | 384666.093 | 1173814.724 | 40 | 384598.247 | 1174286.204 | 75 | 385562.985 | 1175061.671 | 110 | 386425.428 | 1174789.147 |
| 6 | 384556.476 | 1173907.869 | 41 | 384606.000 | 1174305.033 | 76 | 385560.257 | 1175117.297 | 111 | 386088.282 | 1174438.241 |
| 7 | 384441.399 | 1174007.472 | 42 | 384606.000 | 1174316.066 | 77 | 385516.130 | 1175180.672 | 112 | 386088.764 | 1174437.791 |
| 8 | 384441.107 | 1174012.450 | 43 | 384616.255 | 1174327.007 | 78 | 385504.661 | 1175204.860 | 113 | 385942.039 | 1174285.369 |
| 9 | 384439.809 | 1174018.633 | 44 | 384644.354 | 1174349.902 | 79 | 385504.700 | 1175204.925 | 114 | 385783.000 | 1174382.000 |
| 10 | 384433.435 | 1174027.840 | 45 | 384653.197 | 1174363.798 | 80 | 385504.654 | 1175204.869 | 115 | 385728.000 | 1174418.000 |
| 11 | 384425.735 | 1174035.539 | 46 | 384660.378 | 1174379.359 | 81 | 385481.779 | 1175232.997 | 116 | 385579.000 | 1174144.000 |
| 12 | 384420.216 | 1174038.651 | 47 | 384667.259 | 1174414.743 | 82 | 385549.080 | 1175307.714 | 117 | 385516.000 | 1173977.000 |
| 13 | 384410.742 | 1174044.352 | 48 | 384676.936 | 1174431.865 | 83 | 385574.854 | 1175343.237 | 118 | 385561.883 | 1173889.732 |
| 14 | 384405.904 | 1174050.362 | 49 | 384680.691 | 1174435.523 | 84 | 385590.563 | 1175376.899 | 119 | 385526.763 | 1173853.178 |
| 15 | 384406.018 | 1174051.540 | 50 | 384682.607 | 1174418.180 | 85 | 385592.429 | 1175408.422 | 120 | 385465.000 | 1173892.000 |
| 16 | 384409.042 | 1174055.469 | 51 | 384704.492 | 1174396.295 | 86 | 385590.436 | 1175442.697 | 121 | 385449.332 | 1173870.946 |
| 17 | 384413.312 | 1174060.150 | 52 | 384713.447 | 1174392.564 | 87 | 385597.622 | 1175485.432 | 122 | 385433.000 | 1173849.000 |
| 18 | 384419.338 | 1174065.889 | 53 | 384721.272 | 1174348.526 | 88 | 385616.911 | 1175517.772 | 123 | 385423.000 | 1173820.000 |
| 19 | 384429.292 | 1174069.302 | 54 | 384766.507 | 1174342.888 | 89 | 385665.989 | 1175562.176 | 124 | 385406.000 | 1173770.000 |
| 20 | 384439.933 | 1174070.188 | 55 | 384795.729 | 1174345.629 | 90 | 385707.264 | 1175615.911 | 125 | 385434.025 | 1173756.655 |
| 21 | 384455.618 | 1174067.421 | 56 | 384800.400 | 1174346.065 | 91 | 385728.762 | 1175648.811 | 126 | 385253.307 | 1173508.562 |
| 22 | 384463.565 | 1174064.109 | 57 | 384811.076 | 1174349.360 | 92 | 385748.694 | 1175677.721 | 127 | 385146.013 | 1173676.972 |
| 23 | 384473.509 | 1174062.795 | 58 | 384848.616 | 1174371.344 | 93 | 385808.495 | 1175899.255 | 128 | 385025.607 | 1173797.709 |
| 24 | 384484.397 | 1174059.585 | 59 | 384923.481 | 1174452.149 | 94 | 385825.778 | 1176098.009 | 129 | 384917.304 | 1173907.324 |
| 25 | 384500.319 | 1174061.000 | 60 | 384958.508 | 1174465.159 | 95 | 385870.688 | 1176381.140 | 130 | 384882.979 | 1173941.930 |
| 26 | 384514.926 | 1174063.378 | 61 | 384986.147 | 1174494.465 | 96 | 385852.941 | 1176497.500 | 131 | 384868.198 | 1173915.803 |
| 27 | 384528.893 | 1174066.870 | 62 | 384999.042 | 1174513.404 | 97 | 385880.521 | 1176551.114 | 132 | 384847.958 | 1173880.024 |
| 28 | 384540.035 | 1174072.450 | 63 | 385037.889 | 1174483.547 | 98 | 385925.531 | 1176636.610 | 133 | 384921.000 | 1173826.000 |
| 29 | 384550.166 | 1174082.225 | 64 | 385038.929 | 1174483.093 | 99 | 385960.870 | 1176700.629 | 134 | 384928.000 | 1173806.000 |
| 30 | 384563.677 | 1174099.363 | 65 | 385088.396 | 1174475.403 | 100 | 386707.061 | 1176577.216 | 135 | 384965.000 | 1173778.000 |
| 31 | 384569.534 | 1174114.320 | 66 | 385156.299 | 1174452.466 | 101 | 386717.892 | 1176567.399 | 136 | 384915.524 | 1173702.797 |
| 32 | 384574.154 | 1174127.167 | 67 | 385239.000 | 1174444.000 | 102 | 386877.228 | 1176491.693 | 137 | 384946.335 | 1173681.160 |
| 33 | 384577.029 | 1174140.465 | 68 | 385252.751 | 1174444.155 | 103 | 386798.203 | 1176268.628 | 138 | 384921.909 | 1173620.342 |
| 34 | 384579.384 | 1174155.945 | 69 | 385486.437 | 1174534.738 | 104 | 386645.508 | 1176144.915 | | | |
| 35 | 384583.748 | 1174166.350 | 70 | 385513.897 | 1174581.696 | 105 | 386840.891 | 1176100.479 | | | |

